**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

CAMBODIA
Kingdom of Wonder
feel the warmth

**ក្រសួងទេសចរណ៍**

**លេខ** ១១៧ សជណ.ទសគឧ

ថ្ងៃ សុក្រ ១៥កើត ខែ ផល្គុន ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០២១

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី-ខេត្ត**

**កម្មវត្ថុ៖** ស្តីពីការផ្អាកដំណើរការអាជីវកម្មក្លឹបហាត់ប្រាណដើម្បីសុខភាពនៅក្នុង និងក្រៅសណ្ឋាគារ នៅទូទាំងរាជធានី-ខេត្ត ឡើងវិញជាបណ្តោះអាសន្ន។

**យោង៖** - លិខិតលេខ ៧៤៩ សជណ.អគឧ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ក្រសួងទេសចរណ៍

- លិខិតលេខ ៨២២ អយក.រប ចុះថ្ងៃទី២៤ខែកុម្ភៈ ឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ក្រសួងទេសចរណ៍សូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល** ជ្រាបថា អនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការចូលរួមបង្ការ និងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ (COVID-19) ក្នុងអំឡុងពេលព្រឹត្តិការណ៍ ២០ កុម្ភៈ ២០២១ រាល់សកម្មភាពអាជីវកម្ម សេវាកម្មក្លឹបហាត់ប្រាណដើម្បីសុខភាពនៅក្នុង និងក្រៅសណ្ឋាគារនៅទូទាំងរាជធានី-ខេត្ត ត្រូវផ្អាកសកម្មភាពជាបណ្តោះអាសន្ន ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់មានការជូនដំណឹងជាថ្មី។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវអភិបាល** ចាត់ចែង អនុវត្តតាមសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវអភិបាល** ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

រដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងទេសចរណ៍

**ថោង ខុន**

**ចម្លងជូន៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ១៩ (COVID-19)
- មន្ទីរទេសចរណ៍រាជធានី ខេត្ត "ដើម្បីអនុវត្ត"
- គ្រប់ម្ចាស់អាជីវកម្មកីឡាទេសចរណ៍ ក្លឹបហាត់ប្រាណនៅក្នុង និងក្រៅសណ្ឋាគារ
- ឯកសារ កាលប្បវត្តិ